# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ១៧

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៤៨៤

គ.ស. ១៩៤១

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

ឆ្នាំគំរប់ ១៣

ភាគទី ១៧

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព.ស. ២៤៨៤
គ.ស. ១៩៤១

# បញ្ជីរឿង


១ — អំពីអារ្យធម៌របស់ខ្មែរ ស្រង់យកអំពីរឿងមួយដែល លោកសឺដែសជាអ្នករៀបរៀង ៣

២ — អំពីសេចក្ដីចំរើននៃវិទ្យាសាស្ត្រទំនើបថ្មី របស់ខេមរង្សី . . . . . . . . . ៥

៣ — អំពីជនជាតិផ្សេងៗក្នុងសហរដ្ឋឥណ្ឌូស៊ិន . . . . . . . . . . . . . . ១១

៤ — ពង្សាវតារក្រិក ស្រង់យកអំពីគោលចារិកផ្សេងៗក្នុងពង្សាវតារលោក (តមក). ១៧

៥ — សេចក្ដីកត់ហេតុប្លែកៗ (តមក) . . . . . . . . . . . . . . . . . ២០

៦ — រឿងព្រេងខ្មែរៈ "បុរសពីរនាក់តាមខ្ញុំរត់" . . . . . . . . . . . . . . . ២៨


## រូបក្រៅរឿង


ក្រុមប្រាសាទអង្គរ — រូបលោកសង្ឃសូត្រធម៌នៅប្រាសាទតាព្រហ្ម . . . . . ១

# TABLE DES MATIÈRES


Pages

1° Civilisation du Cambodge, extraits d'un article rédigé par M. G. Cœdès .................... 3

2° Le progrès de la science moderne par KHEMARARANSI ..... 5

3° Diverses races de l'Indochine .................... 11

4° Histoire de la Grèce, extraits de divers documents de l'histoire universelle (suite) .................... 17

5° Notes variées (suite et fin) .................... 20

6° Conte populaire cambodgien inédit : "Querelle entre deux personnes" .................... 28

HORS TEXTE :

Groupe d'Angkor — Taprom, le bonze récitant la prière. 1



ក្រុមប្រាសាទនគរ-រូបលោកសង្ឃសូត្រធម៌នៅប្រាសាទតាព្រហ្ម ។

## អំពីអាវុធខ្មែរ

# ស្រង់យកអំពីសៀវភៅរបស់លោកសឺដែស

ក្នុងខណៈដែលស្រុកចម្ប៉ាកើតឡើង តាំងនៅតាមជាយសមុទ្រទិសខាងកើតនៃប្រទេសឥណ្ឌូចិនកាលពីពុទ្ធសករាជ ៦៤៣ នោះ មានប្រទេសហិណ្ឌូមួយទៀតក៏ចាប់តាំងឡើងនៅទិសខាងត្បូងក្នុងសម័យជាមួយគ្នាដែរ ជាប្រទេសរបស់ស្តេចភ្នំ តាមឈ្មោះដែលហៅជាភាសាចិនថា ហ្វូណន ។ កាលពី ព. ស. ៧៤៣ ស្តេចនេះទ្រង់បានពង្រីកអាណាខេត្តចេញទៅ ក៏កើតជាអាណាចក្រមួយយ៉ាងមាំមួនឡើង ដោយទ្រង់ពង្រីកអំណាចចេញទៅពេញដីនៅទិសខាងត្បូង ទឹងផែនដីទៅកណ្តាលជ្រោយប្រទេសឥណ្ឌូចិន ។ អ្នកប្រាជ្ញពង្សាវតារជាតិចិនបានពណ៌នាអំពីប្រទេសនេះថា ជាប្រទេសមានអំណាចមួយ កាន់តាមអារ្យធម៌របស់ឥណ្ឌា ដែលមានក្នុងសាសនាព្រាហ្មណ៍ ទឹងក្នុងពុទ្ធសាសនាសឹងជាទីប្រោសប្រាណក្នុងកដសំណាក់ជាលំដាប់ៗ រៀងៗមក ។

ស្នាមលំអានគ្រឿងប្រដាប់ប្រដាប្រភេទខ្លះរបស់ហ្វូណនមានតែបន្តិចបន្តួចទេ ក្នុងខណៈដែលមានសិលាចារឹក ១ ផ្ទាំងជាភាសាសំស្ក្រឹតដែលត្រូវទឹងសេចក្តីកត់ហេតុរបស់ចិន គឺសិលាចារឹក ២ និយាយពីលទ្ធិវិស្ណុ គេបានរកឃើញនៅក្នុងស្រុកកូសាំងស៊ីន (ក្នុងពលកក់) ទឹងនៅចុងខាងត្បូងស្រុកខ្មែរ ឯសិលាចារឹកមួយទៀត ចារឹករឿងពុទ្ធសាសនា

បានមកពីស្រុកបាទីនៅខាងត្បូងភ្នំពេញ សិលាចារឹកអស់នេះកើតឡើងតាំងអំពី ព.ស. ៩៤៣ ឡើងទៅ ។ មានប្រាសាទជាច្រើន មុនសម័យនគរ នៅក្នុងស្រុកខ្មែរកណ្ដាលនិងទិសខាងត្បូង តំបន់ដែលធ្លាប់ជាទីរុងរឿងរបស់ប្រទេសហ្វូណនជាន់ចាស់ ក៏មិនមានតំបន់ណាមួយល្មមយកជាការពិតបានក្នុងសម័យប្រទេសហ្វូណននោះឡើយ ទុកជាគ្រឿងចម្លាក់ក៏មានទំនងដូចគ្នាដែរ ។ តែទុកជាយ៉ាងណាក៏ដោយ បើមិនមានស្នាមគំនូសពិតៗទេ ដែលជាគំរូយ៉ាងជាន់ចាស់បំផុតនៃវិជ្ជារចនា ទើបគ្រឿងចម្លាក់សម័យបុរាណនៅស្រុកខ្មែរនោះ ក៏គ្រាន់តែឲ្យមានគំនិតគិតស្មានអំពីវត្ថុអស់នេះជាបែបរចនារបស់ហ្វូណន ។

*

* *

បណ្ដាប្រទេសដែលចំណុះហ្វូណននេះ មាននគររបស់ពួកស្ដេចត្រាញ់របស់ជាតិកម្ពុជា ដែលនៅលើតំបន់ទន្លេមេគង្គកណ្ដាល កាលពី ព.ស. ១៥៥០ ។ នាយក (របស់ជាតិកម្ពុជា) ឈ្មោះភវវរ្ម័ន បានតាំងខ្លួនជាឯករាជ្យឡើង ហើយទន្ទ្រានយកដីបានមួយភាគធំរបស់ប្រទេសនៅក្រោមបង្គាប់ (ហ្វូណន) ។ ហេតុនេះហើយ បានជាប្រទេសខ្មែរចុះមកតាំងនៅក្នុងទីទំនាប តាមដងទន្លេមេគង្គខាងក្រោម ដែលជាបុព្វបុរសរបស់ប្រទេសកម្ពុជាសព្វថ្ងៃនេះ ។

## សេចក្ដីចំរើននៃវិទ្យាសាស្ត្រ

មនុស្សដែលបានទទួលការសិក្សាមកហើយ គង់សង្កេតឃើញច្បាស់ថា ស្រុកទេសក្នុងសម័យមុននឹងសម័យឥឡូវនេះ មានសភាពខុសគ្នាឆ្ងាយណាស់ ទាំងគ្រឿងប្រើប្រាស់នានាប្រការ ទាំងយានជំនិះ ទាំងគ្រឿងសំលៀកបំពាក់ ទាំងគេហស្ថាន រហូតដល់អាហារភោជន គឺថាសព្វសារពើទាំងអស់ក្នុងលោក តែងមានអាការប្រែប្រួលផ្លាស់រូបផ្លាស់សភាពដើមទៅទាំងអស់ ។ ផលនៃសេចក្ដីប្រែប្រួលនេះ មកអំពីវិទ្យាសាស្ត្រចំរើនឡើងយ៉ាងសំបើម ទើបធ្វើឲ្យលោកនេះផ្លាស់រូបរាងដើមស្ទើរតែមិនស្គាល់យ៉ាងច្បាស់ណាស់ ដូចជាពីដើមមានតែរទេះគោ-ក្របី ឬរទេះសេះ ឥឡូវក៏ប្រែទៅជារថយន្ត រថភ្លើង ពីដើមមានតែទូកប៉ោវទូកអុំ ទូកក្ដោង ឬសំពៅកេត្រា ឥឡូវមានកប៉ាល់តូច-ធំបើកចេញទៅក្នុងមហាសមុទ្រឥតញញើតនឹងខ្យល់ព្យុះ ។ សម័យនេះ ការគមនាគមចំរើនឡើងយ៉ាងរួសរាន់ ការទៅមកកាន់គ្នាក្ដី ការជូនដំណឹងដល់គ្នាក្ដី សឹងហើសឆាប់ទាន់ចិត្តលើសសម័យដើមឆ្ងាយណាស់ ព្រោះយើងមានវិទ្យុ, វិទ្យុទូរសព្ទ, វិទ្យុទូរលេខ នឹងមានជំនិះទំនើបថ្មី ដូចជារថយន្ត រថភ្លើង នឹងយន្តហោះជាដើម សុទ្ធតែជារបស់កើតថ្មីទាំងអស់ ។

បណ្ដាវត្ថុដែលគេគិតប្រឌិតធ្វើឡើងទាំងប៉ុន្មាន សុទ្ធតែនាំឲ្យបានស្រួលបានសុខប្បាយ បានសេចក្ដីសុខដល់មនុស្សយើងទាំងអស់ នេះជា

ផលដែលកើតមកអំពីសេចក្តីចំរើនតាមផ្លូវវិទ្យាសាស្ត្រ ។ មនុស្សដែលគេហៅថា "អ្នកប្រាជ្ញវិទ្យាសាស្ត្រ" នេះហើយដែលលះបង់ពេលវេលាច្រើនស្រាវជ្រាវរកគិតធ្វើរបស់ឬវត្ថុចំឡែកៗឡើង ដើម្បីជាប្រយោជន៍ដល់មនុស្សផងគ្នា ៖ តែដោយហេតុមនុស្សយើងនៅមានលោភ ក្រោធ វង្វេងគប់នៅខាងក្នុងខន្ធសន្តាន មិនគិតធ្វើចំពោះរបស់ដែលមានប្រយោជន៍ដល់មនុស្សផងគ្នាតែម្យ៉ាងទេ គឺនាំគ្នាកសាងគ្រឿងប្រហារមនុស្សនិងវត្ថុដែលមនុស្សខំកសាងឡើងឲ្យហិនហោចខូចខាតទៅទៀតផង ហេតុដូច្នេះបានជាយើងមើលឃើញបម្លាំងសម័យនេះ មានអាការសាហាវយ៉ាងសំបើម ដូចជាគ្រាប់បែក, កាំភ្លើងតូច-ធំ, រទេះអណ្តើក, ប៉មបន្ទាយ, កប៉ាល់ចម្បាំងធំៗនិងកប៉ាល់មុជទឹក, មេដែក, គ្រាប់បែកបណ្តែតក្នុងទឹកពាក់ជ្រៅ, យន្តហោះចម្បាំងទំនើបថ្មី, គ្រឿងដុះបញ្ចាំងយន្តហោះ, គ្រឿងស្តាប់សំឡេងយន្តហោះ, កប៉ាល់សម្រាប់ប្រហារកប៉ាល់មុជទឹកបែបថ្មី ៗលៗ និងវត្ថុដទៃៗទៀតច្រើនជាអនេក ៗ ឃើញថាសង្គ្រាមក្នុងបច្ចុប្បន្ននិងអនាគតនោះមានអាការសាហាវមុខគួរស្ញប់ស្ញែងជាទីបំផុត ។ គ្រឿងប្រហារអស់នេះ ក៏កើតឡើងដោយស្នាដៃនៃអ្នកប្រាជ្ញវិទ្យាសាស្ត្រដែរ ដូច្នេះទើបយើងមើលឃើញច្បាស់ថា របស់ណាដែលមានគុណអនន្ត របស់នោះក៏មានទោសមហន្តដែរ ។

បណ្តាគេហស្ថានធំៗ និងខ្ពង់ខ្ពស់នៅទ្វីបនុរុបនិងអាមេរិក ស្ទើរតែ

សម្រេចដោយស្នាដៃនៃពួកវិស្វករ និងអ្នកប្រាជ្ញវិទ្យាសាស្ត្រទាំងឡាយ គិតធ្វើបែបកសាងឡើង ហេតុនេះបានជាក្នុងលោកនេះមានផ្ទះខ្ពស់ទីង ច្រើនជាន់ដល់ ៨៦ ជាន់ ជាគេហស្ថានដែលមានកំពស់ខ្ពស់បំផុតក្នុងលោក មានស្ពានធ្លងទន្លេវែងៗ មានឧមង្គ មានរថភ្លើងរត់បានក្នុងដី មានថ្នល់នៅក្រោមដី ក្រោមទឹក និងធ្វើរលើដំបូលផ្ទះ ផ្លូវធ្លងកាត់ភ្នំជាដើម ។ល។ សុទ្ធតែនឹងពោលបានដោយពេញមាត់ថា ការរៀបចំភូមិប្រទេសរបស់លោកនេះ ឲ្យបានស្រួលសប្បាយដល់មនុស្សលោកនេះ សឹងសម្រេចដោយស្នាដៃនៃអ្នកវិទ្យាសាស្ត្រទាំងឡាយ ។

ឯគ្រឿងថ្នាំសម្រាប់រក្សារោគបែបសម័យថ្មីទៀត ក៏មានផលយ៉ាងវិសេសក្នុងការព្យាបាលជម្ងឺផ្សេងៗ គ្រឿងថ្នាំដែលផ្សំឡើងអំពីធម្មជាតិនិងផលដែលកើតអំពីវិធីផ្សំធាតុនោះ មានច្រើនយ៉ាងច្រើនប្រការ ត្រាតែយើងមានថ្នាំសម្រាប់រក្សារោគរាប់ដោយហ្មឺនយ៉ាង ទាំងថ្នាំលាប ទាំងថ្នាំផឹកខាងក្នុង សុទ្ធតែជាគ្រឿងប្រើជំនួសថ្នាំឫសឈើ ស្លឹកឈើនិងកំណាត់ឈើជាដើមនោះ ដែលយើងធ្លាប់ប្រើដាក់ឆ្នាំងស្ងោរ ឬត្រាំទឹកក្តៅកាលពីជាន់ដើមនោះ ឥឡូវនេះ យើងមានថ្នាំច្រើនមុខ ទាំងថ្នាំទឹក ថ្នាំគ្រាប់ និងថ្នាំម្សៅជាដើម សុទ្ធតែស័ក្តិសិទ្ធិសម្រាប់ម្ចាប់រោគផ្សេងៗ បានយ៉ាងឆុតឆាប់ វេលានេះ យើងជិតមានជ័យជំនះលើធម្មជាតិហើយ ព្រោះដោយអំណាចថ្នាំនេះឯង ដែលធ្វើឲ្យជីវិតមនុស្សប្រែរួចពីសេចក្តីស្លាប់

ក្នុង ១ ឆ្នាំ ៗ ជាចំនួនច្រើនដែរ ៗ រោគដែលសាហាវបំផុត ដូចជាអហិវាតករោគ, គ្រុនចាញ់, ខាន់ស្លាក់, ឆ្កែឆ្កួតខាំ, ឡាប៉េស្ត៍, រោគរបេងរីងរៃ ៗ ល ៗ អ្នកប្រាជ្ញវិទ្យាសាស្ត្រ និងគ្រូពេទ្យបានរិះរកថ្នាំបំបាត់រោគអស់នោះដោយម៉ឺងម៉ាត់ ទាល់តែបានសម្រេចដូចបំណង ក្រៅពីនេះវិជ្ជាវិទ្យាសាស្ត្របានប្រទះឃើញវិធីរក្សារោគបែបថ្មីម៉្យាងទៀត ដោយអាស្រ័យពន្លឺអគ្គិសនីជាគ្រឿងចុះត្រួតមើលអវយវៈខាងក្នុងរាងកាយ ហើយគេបានរកឃើញធាតុម៉្យាងដែលគេបានដោយកម្រនិងមានដំឡៃបំផុតក្នុងលោកមកប្រកបជាគ្រឿងរក្សារោគម្រេញនិងរោគដំបៅល្អួយរលេះបានយ៉ាងស័កសិទ្ធិ ៗ

តាមទំនងដែលពោលមកនេះយើងមើលឃើញថា កិច្ចការរបស់អ្នកប្រាជ្ញវិទ្យាសាស្ត្រ ទុកដូចជាអ្នកទំនុកបំរុងលោកនេះឲ្យបានសុខសប្បាយនិងបានស្រួល ឥតរោគភ័យវិបត្តិនានា ភ័យដែលកើតអំពីធម្មជាតិ ដូចជាទឹក ខ្យល់ជាដើម ក៏រកឧបាយបន្ទោចង់ឲ្យបានស្រាល ហើយនិងចាប់យកកំឡាំងទឹក-ខ្យល់នោះមកប្រើជាប្រយោជន៍ថែមទៀតផង ដូចជាកំឡាំងគ្រឿងយន្តនានាដែលមាននៅក្នុងសព្វថ្ងៃនេះ ៗ

គង់ដឹងឮពល់គ្នាហើយថា ពន្លឺរស្មីនៃដួងព្រះអាទិត្យបានធ្វើប្រយោជន៍ដល់មនុស្ស, សត្វ និងព្រឹក្សជាតិរ្វៅ ៗ ពន្លឺកំដៅរបស់ធម្មជាតិអ្នកប្រាជ្ញវិទ្យាសាស្ត្រដែលមានខួរក្បាលដ៏មុតស្រួចជាអ្នកគិតតែពីរកឧបាយ

ធ្វើប្រយោជន៍ដល់មនុស្សក្នុងលោកជនគ្នា បានគិតធ្វើគ្រឿងយន្ត គ្រឿងចក្រដែលប្រើកំដៅអំពីដួងអាទិត្យ ជំនួសកំដៅដែលកើតអំពីភ្លើងធម្មតាបានទៀតផង ។ វេលានេះ អ្នកប្រាជ្ញវិទ្យាសាស្ត្រកំពុងស្រាវជ្រាវល្បងមើលថា ពន្លឺនឹងកំដៅរបស់ដួងអាទិត្យនេះ យើងនឹងប្រើធ្វើប្រយោជន៍អ្វីទៀតបានខ្លះ?... យើងលុមទឹកស្មានថា ក្នុងកាលតទៅខាងមុខទៀត គ្រឿងយន្តកំឡាំងចំហាយទឹកដែលធ្លាប់ប្រើឧសអង្កាមធ្យូងប្រេងសាំង ប្រេងកាត ជាមេភ្លើងកំដៅនោះ គង់តែនឹងបាត់អស់ទៅ ហើយនឹងមានគ្រឿងយន្តប្រើកំដៅអំពីដួងអាទិត្យជំនួសមិនខាន ។

លោកនេះ បើខ្វះដែក នឹងគង់ទ្រង់ទៅជារូបលោកដូចសព្វថ្ងៃនេះមិនបានទេ ព្រោះដែកជាវត្ថុដ៏សំខាន់បំផុតក្នុងលោក ក្នុងការកសាងគេហស្ថាន ទីងៈកងកនមន្ទីរនានាប្លែក ៗ ច្រើនអនេកប្រការ ។ បើលោកនេះ ប្រាសចាកគ្រឿងកសាងហើយ មុខជានឹងសាបសូន្យទៅវិញជាមិនខាន ។ សូម្បីក្នុងសម័យមុនដែក អារ្យធម៌របស់លោកបានចំរើននឹងមានមកមុនហើយក៏ដោយ តែខូចខាតពេលវេលាជាយូរអង្វែង នឹងមិនសូវមានផង ។ លុះមកដល់សម័យដែកនេះ ទើបធ្វើឲ្យលោកមានសេចក្តីចំរើនឡើងយ៉ាងរហ័ស មានគេហស្ថានយ៉ាងវិចិត្រល្អនានាប្រការ មានយន្តហោះថែបសម័យ មានរថយន្ត កប៉ាល់ រថភ្លើង ។ល។ ដែលជាសាក្សីនៃសេចក្តីចំរើនរបស់លោក រួមសេចក្តីថា បណ្តាសេចក្តីចំរើន

របស់លោកនេះមានចំណែកដែកដល់ទៅ ៦០ % ជាគ្រឿងប្រកបសេចក្តីចំរើនដល់លោក ៗ អ្នកប្រាជ្ញវិទ្យាសាស្ត្រខំរិះរកវិធីធ្វើឲ្យដែកមានសាច់ស្វិតទាំងជាប់មាំមួនដោយវិធីលាយផ្សំទាំងលោហៈឯទៀតៗ ធ្វើមិនឲ្យមានស្នឹម ល្មមទទួលដឹងថា លោកអាស្រ័យដែកជាស្ថូលនៃអារ្យធម៌ ទាំងត្រូវអាស្រ័យដែកតទៅទៀតជាអង្វែងណាស់ ៗ

(មានត)

# អំពីជនជាតិក្នុងប្រទេសឥណ្ឌូស៊ីន

**ជាតិយួន** — ជាតិយួនច្រើនតែមានរាងតូចៗសក់លើងឈរត្រង់ ទំរង់មុខមានសាច់លឿងហួសថ្ពាល់ ភ្នែកតូច សម្បុរស្បែកក្លឹ ។ ជនជាតិយួនជាច្រើនកេស៊ីធ្វើស្រែចំការច្បារដំណាំ នៅតាមមាត់សមុទ្រមានពួកយួនខ្លះនេសាទត្រី ។ គ្រឿងបរិភោគៈ យួនប្រើបាយ, សាច់ជ្រូក, ត្រី និងផឹកទឹកតែ ។ យួនធ្វើទឹកត្រីជាច្រើន ដែលហៅថា ទៀក-មុំ សម្រាប់ផ្សំលាយនឹងអាហារភោជនផ្សេងៗ ។ ជនជាតិយួនមានកូនចៅសាយភាយរហូតណាស់ សព្វថ្ងៃមានជាតិយួននៅប្រទេសតុងកាំង អណ្ណាមនិងកូសាំងស៊ីន ហើយមានសាយភាយចូលទៅក្នុងដែនដីលាវទៀតផង ។ អារ្យធម៌របស់យួនបានទទួលមកពីប្រទេសចិន ។

**ជាតិចាម** — ជាតិចាមនៅក្នុងដីអណ្ណាម២អន្ទើកក្នុងកូសាំងស៊ីនមាននៅក្នុងខែត្រតៃនិញនិងចូដុក ហើយក្នុងស្រុកខ្មែរមាននៅក្នុងខែត្រកំពតនិងបាត់ដំបង ។ សព្វថ្ងៃជនជាតិនេះកំពុងតែសាបសូន្យលាយអស់ទៅ ។ កាលពីដើមនោះជនជាតិនេះ ជាប្រជាជាតិមានបុទ្ធិអំណាចមួយដែលច្បាំងតទល់នឹងទ័ពនៅទិសខាងជើងមានជ័យជំនះ ហើយឈ្នះទ័ពខ្មែរនៅទិសខាងត្បូង ។ មានពួកចាម១ពួកទៀតនៅជិតក្រុងបាងកក និងនៅលើឈូងសមុទ្រសៀម ។ ពួកប្រុសៗច្រើនមានរាងកាយធំៗ តែមិនសូវខ្លាំង ពួកស្រីៗច្រើនមានរាងតូចៗសម្បុរសណ្ដែកបាយ (សម្បុរផ្កា) ។ ជនជាតិ

នេះច្រើននៅផ្ទះឈើទាបៗ របររកស៊ីធ្វើស្រែ, ដាំពោត, កប្បាស, សណ្ដែកជាដើម ហើយចិញ្ចឹមជីវិតដោយឡែកៗពីគ្នា មិនសូវមានរឿងឈ្លោះទាស់ទែងគ្នា យូរៗមានរឿងសម្លាប់គ្នាម្ដងៗ ។ អារ្យធម៌របស់ជនជាតិនេះបានទទួលមកពីប្រទេសឥណ្ឌា ទាំងចំណែករបៀបសរសេរ របៀបសាសនា និងរបៀបកសាងសម័យបុរាណ ។ មានពួកចាមខ្លះកាន់តាមរបៀបមុស៊ុល្ម៉ាន ដោយហេតុពួកចាមធ្វើតាមរបៀបមុស៊ុល្ម៉ាននេះហើយដែលនាំឲ្យគាន់ប្រឡំនឹងពួកចាម ៦០.០០០ នាក់នៅស្រុកខ្មែរនិងស្រុកកូសាំងស៊ីនដែលកាន់នឹងប្រតិបត្តិតាមសាសនាមហាម៉ាត់ ។ ពួកចាមនេះជាពួកនៅទូក មានធ្វើខ្ទមបន្តិចនៅលើទូកផង ហើយមិននៅលាយច្របល់នឹងជាតិដទៃទៀតទេ សេពគប់តែនឹងពួកចាមមុស៊ុល្ម៉ានដូចគ្នា ។

អំពីជនជាតិខ្មែរ — ជាតិខ្មែរមានកងធំ មានសក់អង្កាញ់ៗក្ដួកត្រង់ ជាតិខ្មែរមានឈាមជ័រកាត់ហិណ្ឌូ មះលូ នឹងថៃ ។ មហាអាណាចក្រខ្មែរ ជនជាតិខ្មែរមិនមែនត្រឹមស្រុកខ្មែរនេះទេ មាននៅខាងត្បូងទៀងខាងលិចដែនកូសាំងស៊ីននឹងក្នុងស្រុកសៀម ១ ចំណែកផង ។ ធ្លាប់ធ្វើសឹកសង្គ្រាមនឹងពួកចាម, យួន នឹងសៀម ខ្មែរតែងធ្វើចម្បាំងកំងដល់ឥតស្រាក ដល់មកឆ្នាំ ១៨៦៤ ជាតិបារាំងសែសចូលគ្រប់គ្រងស្រុកខ្មែរ ទើបស្ងប់ការចលាចល ។ ប្រជាជនខ្មែរជាអ្នករកស៊ីធ្វើស្រែចំការ ចិញ្ចឹម

សត្វ ចាប់ត្រី ផ្ទះសំបែងច្រើនខ្ពស់ៗ ស្រឡះក្រោមហើយនៅដាច់ៗពីគ្នា មិនជុំគ្នាទេ ជនជាតិខ្មែរជាអ្នកកាន់ព្រះពុទ្ធសាសនា ជាប្រជាជនស្លូតសុភាពចិត្តត្រជាក់ ។

អំពីជាតិថៃនិងជាតិលាវ — ជនជាតិនេះចុះមកពីទិសខាងជើងហើយមានលំនៅៗសព្វថ្ងៃនេះ គឺខាងជើងស្រុកតុងកាំង ស្រុកលាវ, ស្រុកសៀម, ស្រុកភូមា ។ ជាតិថៃជាជាតិឈ្លាសវៃ មានអំណាចច្រើនហើយចេះប្រមូលប្រជាជនដែលនៅជុំវិញខ្លួនឲ្យនៅក្រោមអំណាចបានហើយចូលចិត្តគេលំនៅក្នុងទីមានផ្លូវទឹក ។ ជនជាតិនេះមានពងកាយយ៉ាងកណ្ដាល គេពិនិត្យឃើញសែស្រឡាយពួកនេះមានច្រើនពួកដូច្នេះ:

១ ពួកថូ — ពួកថូនៅប្រទេសតុងកាំងខាងលើ នៅក្នុងអំណាចពួកយួន ចូលចិត្តប្រើពណ៌ផ្ទៃមេឃជាគ្រឿងសំលៀកបំពាក់ ផ្ទះសំបែងច្រើនខ្ពស់ៗ ស្រែចំការរបស់ជនពួកនេះនៅតាមច្រកភ្នំ ឬទប់ទឹកតាមជើងភ្នំធ្វើជាថ្នាក់ៗ សម្រាប់ធ្វើស្រែចំការ ។ ជនពួកនេះមានពងកាយមាំខែងរ៉ែងហើយជាអ្នកកក់ពាក់ស្រួកយ ។

២ ពួកម៉ៀង — ពួកមៀងជាញាតិវង្សសែស្រឡាយជាមួយនឹងពួកថូដែរ តែគ្រឿងសំលៀកបំពាក់ប្រផ្សេងៗ ធ្វើតាមរបៀបចិន ។ ពួកនេះក៏ខែងរ៉ែងនិងឧស្សាហ៍ធ្វើការណាស់ ។ ពួកនេះនៅក្នុងដែនតុងកាំងទិសខាងជើងឆៀងខាងកើត ។

៣ ពួកថៃស– ពួកថៃសនៅតាមទន្លេក្រហមហើយមានរបៀបដែនដូច ពួកថៃដែរ ឯពួកថៃសឯទៀតៗ គេឃើញមាននៅលើស្ទឹងខ្មៅខាងលើ និងស្រុកហ្លួងព្រះបាងខាងជើង ពួកនេះធ្វើផ្ទះស្រឡះក្រោមដែរ រកស៊ី ចូលចិត្តភ្លេងនិងចំរៀង ៗ ពួកស្រីៗពាក់អាវស ៗ

៤ ពួកថៃខ្មៅ– ពួកនេះនៅតាមទន្លេខ្មៅនិងទន្លេក្រហម ហើយនៅផ្ទះស្រឡះក្រោមដែរ ពួកនេះច្រើនមានរាងកាយធំៗ ៗ

៥ ពួកថៃនូ– សព្វថ្ងៃនេះមានចំនួនប្រមាណ ២២.០០០ នាក់ ច្រើនធ្វើផ្ទះនៅស្រឡះក្រោមដែរ ហើយនៅប្រមូលគ្នាជាពួកៗជាភូមិធំៗ រកស៊ីធ្វើស្រែ, ទំនប់ទឹក ស្រែនៅតាមភ្នំធ្វើនៅកន្លែងដែលបានដុតព្រៃហើយ ក្រៅពីនេះរកស៊ីដាំពោត, ដាំកញ្ឆា, ដាំកក់, ដាំសណ្តែក, លក់ល័ក្ត, លក់កញ្ឆានិងថ្នាំជក់ ៗ សំពត់បង្កច្រើនប្រើសូត្រហើយចេះត្បាញល្អណាស់ផង ៗ ពួកស្រីៗទុកសក់បួងខ្ពស់ឡើងលើ ៗ

៦ ពួកលាវ– ពួកលាវមានចំនួនច្រើនបំផុតប្រមាណ ៦០០.០០០នាក់ នៅតាមមាត់ទន្លេមេគង្គខាងជើងស្រុកចិន និងតាមព្រំប្រទល់ដែនស្រុកខ្មែរ ផ្ទះលាវមានលក្ខណៈស្រឡះក្រោមដែរ ៗ អាហារគេជន ប្រើបាយ, ត្រី, សាច់សត្វផ្សេងៗនិងផ្លែឈើ ៗ លាវជាជនជាតិប៉ុនប៉ោខាងពិធី ប្រើទូកណាស់ ពួកស្រីៗយកចិត្តទុកដាក់ធ្វើការនៅផ្ទះសំបែង ហើយពួកដែលនៅតាមភ្នំ ច្រើនធ្វើស្រែចំការ ៗ ឯបុណ្យទានចំឡែកៗគឺបុណ្យ

ដែលគេនិយមធ្វើតាមវត្តនឹងបុណ្យឆ៉ាន (បុណ្យនេះគេប្រជុំពួកក្រមុំកំឡោះឲ្យដោះសាសំដីគ្នាលេងកំសាន្តឥតប្រកាន់) ។

អំពីពួកម៉ីយឬព្នងឬខា — ម៉យ ឬ ព្នង ឬ ខា នៅលើដីខ្ពស់ស្រុកអណ្ដាមស្រុកខ្មែរ នឹងស្រុកលាវ ។ ពួកនេះមានរាងកាយច្រើនតូចៗ មានក្នុកត្រង់ សម្បុរស្បែកដំដែង សក់ក្រញាញ់ ។ មានមួយពួកនោះនិយាយភាសាចាមបុរាណ មួយពួកទៀតនិយាយភាសាខ្មែរបុរាណ ។ ពួកនេះមិនសូវនៅនឹងជាប់ក្នុងកន្លែងមួយៗទេ ចូលចិត្តខាងបរបាញ់សត្វព្រៃណាស់ ។ នៅក្នុងដែនឥណ្ឌូស៊ីនខាងជើងដែលមានភ្នំជាច្រើនគេឃើញពួកនេះមានចំនួនច្រើនពួកដែរ ។

អំពីពួកមនឬយ៉ាវ — ពួកនេះមិនចុះទៅដីទាបជាង ២០០ ម៉ែត្រពីទឹកសមុទ្រទេ ឯពួកនេះចុះមកពីស្រុកចិនហើយមកនៅក្នុងឥណ្ឌូស៊ីននេះតាំងពី៤០០ឆ្នាំមកហើយ ។ ពួកនេះមានដងខ្លួនកំពស់១ម៉ែត្រ៥៨សង់ទីម៉ែត្រ មានថ្ងាសសំប៉ែត មានចំនួនប្រមាណ ៥០.០០០ នាក់ដែលនៅលើភ្នំផ្សេងៗនៅតុងកាំងនឹងស្រុកលាវខាងលើ ។ មានរឿងព្រេង ១ ដំណាលតៗគ្នាមកថា ពួកជីដូនជីតារបស់ជាតិមននេះខាងប្រុសជាតិជាឆ្កែលឿង ហើយខាងស្រីជាតិជាក្សត្រីជាតិចិន ហេតុនេះហើយបានជាគេហាមមិនឲ្យស៊ីសាច់ឆ្កែ ហើយគេច្រើនឃើញមានរូបឆ្កែប៉ាក់នៅនឹងសំពត់អាវរបស់ស្រីៗ ។ ជនពួកនេះមានថ្វីដៃចំណាប់ណាស់ ពួកជាងដែកបេះ

សិតដែកធ្វើអាវុធនិងប្រដាប់ធ្វើស្រែ ពួកជាងមាស-ប្រាក់ចេះវិធីបញ្ចុះថ្នាំនឹងមាស-ប្រាក់ និងក្បាច់គ្រឿងប្រាក់ផ្សេងៗ ។ មានស្មៀនខ្លះចេះអក្សរចិនផង ។ ប្រពន្ធបរិភោគបាយជាមួយនឹងប្តី ផ្ទះនៅស្រឡះក្រោមដូចផ្ទះខ្មែរដែរ ។ ទឹកប្រើប្រាស់នឹងផឹក គេយកបំពង់ឫស្សីដាក់ភ្ជាប់គ្នាបង្ហូតចូលទៅក្នុងផ្ទះហូតដល់ផ្ទះបាយ ។ រាល់ៗល្ងាចវេលាដែលត្រឡប់មកពីធ្វើការ គេតែងលាងជើងដោយទឹកក្តៅជានិច្ច ។

អំពីពួកម៉ែវ— ពួកនេះមិនព្រមចុះហួសទាបជាងកំពស់ ១០០០ ម៉ែត្រទេ ភូមិរបស់ជនពួកនេះមានចំនួនតិចមិនគុះគរ ហើយតាំងនៅលើកំពូលភ្នំផង ។

ជនពួកនេះជាពួកមានឥស្សរភាពមែនៗ ហើយជាអ្នកពូកែធ្វើការងារ នឹងចូលចិត្តខាងធ្វើចម្បាំង ។ ភាសាសំដីរបស់ជនពួកនេះមានជារបស់ខ្លួនដោយឡែក មានគ្រឿងសំលៀកបំពាក់ជាប់មកតាំងពីដើមមិនប្រែប្រួល មិនចេះអក្សរ គ្មានប្រក្រតិទិន មិនចេះប្រើចង្កឹះ លំនៅរបស់ពួកនេះនៅនឹងដី ពួកនេះចូលចិត្តដុតព្រៃធ្វើស្រែ ចូលមកនៅក្នុងប្រទេសឥណ្ឌូចិន តាំងពី ២០០ ឆ្នាំមកប៉ុណ្ណោះឯង ។

ក្នុងគ្រានេះ ព្រះបាទអាឡេក្សង់ដ្រ៍ទ្រង់ព្យាយាមធ្វើតាមគ្រោងការដែលពួកក្រិកគិតធ្វើមកជាយូរអង្វែងហើយនោះឲ្យបានសម្រេចដាច់ស្រេចទៅ ពោលគឺតាំងចិត្តច្បាំងឲ្យឈ្នះទ្វីបអាស៊ី ទីងកៀរគរប្រមូលមាសប្រាក់យកចូលទៅក្នុងទ្វីបឧរុប ។ គំនិតនេះ ទាំងអាថែនទាំងស្ប៉ាតធ្លាប់គិតទឹកមកជាយូរហើយដែរ តែមិនមានអ្នកពូកែល្មមគិតគូរធ្វើការឲ្យសម្រេចទៅបាន ។ មួយវិញទៀត ការធ្វើសង្គ្រាមសងសឹកនឹងប្រទេសប៉ែរ្ស៍នេះ ជារបស់ដែលពួកក្រិកត្រូវការណាស់ ហេតុនេះជាឱកាសល្អរបស់ព្រះបាទហ្វីលិបនិងព្រះបាទអាឡេក្សង់ដ្រ៍ដែលទ្រង់នាំយករឿងនេះមករំពុក ជារនាំងបំបាំងមុខសម្រាប់ធ្វើការធំតាមចំណង់របស់ខ្លួន ។

**អំពីការច្បាំងលុកលុយចូលមកទ្វីបអាស៊ី** — ខណៈនោះជាឱកាសល្អ ចួនជាមានរឿងកើតឡើងនៅប្រទេសប៉ែរ្ស៍ ធ្វើឲ្យប្រទេសប៉ែរ្ស៍ទន់ខ្សោយកំ-ឡាំងចុះទៅជាច្រើន ដោយមានអ្នកសម្រេចរាជការនៅទ្វីបអាស៊ីតូចឈ្មោះស៊ីរុស (Cyrus) មានចិត្តក្បត់ បានជួលពួកក្រិកចំនួន ១ ម៉ឺននាក់មកធ្វើជាទាហានហើយបំបះបំបោរក្បត់នឹងក្សត្រប្រទេសប៉ែរ្ស៍ដែលជាព្រះជេដ្ឋារបស់ខ្លួន លុះដល់កើតចម្បាំងឡើង ស៊ីរុសក៏ស្លាប់ក្នុងចម្បាំងទៅ ឯពួកទាហានក្រិកទាំងម៉ឺនក៏សល់នៅក្នុងទីនោះឯង ហើយតាំងសេនោហ្វុងជាអធិបតី ជាសិស្សរបស់សូក្រាត ហើយក៏ចាប់ធ្វើ

ការរុករានទន្ទ្រានទៅមុខទៀតរហូត ១៥ ខែ អស់រយៈផ្លូវ ៦៤០០ គីឡូម៉ែត្រ ដើរទ័ពកាត់ប្រទេសផ្សេងៗ ដែលខ្លួនមិនស្គាល់ ហើយច្បាំងមានជ័យជំនះពួកអ្នកស្រុកសព្វអន្លើ ពួកនេះលុះត្រឡប់មកប្រទេសក្រិកវិញក៏ក្លាយទៅជាអ្នកអង់អាចក្លាហានមិនបេះខ្លាចអ្វី ឯសត្រូវដែលពួកនេះតែងកោតខ្លាចនោះមាន ៤ យ៉ាងគឺ ការឃ្លាន, ស្រេក, រងា និងក្តៅ ។

ព្រះបាទអាឡេក្សង់ដ្រ៍ទ្រង់ជ្រើសរើសយកតែទាហានពូកែៗ ទៅជាមួយនឹងព្រះអង្គ មានទាហានថ្មើរជើងចំនួន ៤ ហ្មឺន ទាហានសេះចំនួន ៥ ពាន់ ទឹងទាហានដែលអង់អាចក្លាហាន សឹងមានសង្ឃឹមទុកជាមុនថា បើមានជ័យជំនះត្រឡប់មកវិញទុកជាកិត្តិយសដ៏ខ្ពង់ខ្ពស់នឹងមានសម្បត្តិស្តុកស្តម្ភផង ទុកជាព្រះបាទអាឡេក្សង់ដ្រ៍ មិនទ្រង់ប្រទានរង្វាន់ ក៏នៅមានឱកាសទៅប្លន់ដណ្តើមទ្រព្យសម្បត្តិពីពួកចាញ់បានដែរ បើចាញ់ ក៏សុខចិត្តស្លាប់តែម្តង ។ ទាហានរបស់ព្រះបាទអាឡេក្សង់ដ្រ៍ពូកែជាងទាហានប៉ែរ្ស៍គ្រប់យ៉ាង ទាំងវិធីហាត់ទាំងវិធីច្បាំងដែលជារបៀបថ្មីៗក្នុងសម័យនោះ ។ ចំណែកខាងប្រទេសប៉ែរ្ស៍នោះតាំងអំពីកាលកើតសង្គ្រាមនឹងក្រិកគ្រានោះមក វិជ្ជាការខាងទាហានមិនបានចំរើនឡើងសោះ ថែមទាំងអាណាប្រជារាស្ត្រ នាំគ្នាស្អប់ក្សត្រគ្រងរាជ្យរបស់ខ្លួនកាន់តែច្រើនឡើង ហើយត្រូវការចង់ផ្លាស់ចៅហ្វាយថ្មីជានិច្ច ហេតុនេះបានជាព្រះបាទអាឡេក្សង់ដ្រ៍ទ្រង់ច្បាំងឈ្នះប្រទេសប៉ែរ្ស៍

បានដោយងាយ តែមានសេចក្ដីលំបាកមួយយ៉ាងដោយភូមិប្រទេសនោះធំទូលាយហួសពេក ជាហេតុនាំឲ្យពាហនក្រិកមានចិត្តធុញទ្រាន់ ថែមទាំងមានចិត្តនឹករលឹកដល់ប្រពន្ធកូននៅឯក្រោយនោះផង ។ ប៉ុន្តែសេចក្ដីព្យាយាម និងឈ្លាសវៃរបស់ព្រះបាទអេឡេក្សង់ដ្រ៍ជាគ្រឿងបន្ធូរបន្ថយសេចក្ដីលំបាកអស់នេះបញ្ចប់បានដោយស្រួល ។

អំពីការលុកលុយទ្វីបអាស៊ីតាមសមុទ្រមេឌីតេរ៉ាណេ. — ព្រះបាទអាឡេក្សង់ដ្រ៍ទ្រង់នាំពួកពលទៅឡើងគោកជិតស្រុកត្រ្វា (Troie) ទ្រង់ចាត់ចែងធ្វើពិធីបួងសួងព្រះអាស៊ីល(Achille)ជាទេវរូបសម្ពន្ធមិត្តជាតិក្រិកសម្រាប់កងទ័ពលើកទៅច្បាំងតទល់នឹងអាស៊ី មិនយូរប៉ុន្មានក៏បានជួបប្រទះនឹងកងទ័ពប្រទេសប៉ែរ្ស៊ ក៏បាក់បែកខ្ចូចខ្ចីទៅ ហើយបណ្ដាស្រុកប៉ែរ្ស៊ដែលនៅតាមមាត់សមុទ្រក៏ធ្លាក់ទៅនៅក្នុងកណ្ដាប់ដៃនៃព្រះបាទអាឡេក្សង់ដ្រ៍ដោយហេតុកងទ័ពជើងទឹកប្រទេសប៉ែរ្ស៊មិនហ៊ានមកប៉ះមុខទ័ពអាឡេក្សង់ដ្រ៍ (ព. ស. ២០៩ មុន គ. ស. ៧៣៤ ។

ក្នុងឆ្នាំជាបន្ទាប់តមក ព្រះបាទអាឡេក្សង់ដ្រ៍ទ្រង់លើកទ័ពដើរចូលទៅក្នុងភាគកណ្ដាលនៃទ្វីបអាស៊ីតូច នៅទីនោះ ក្សត្រដារីយុស (Darius) ទ្រង់នាំទ័ពមានចំនួនពលដល់ទៅបីសែនមកតាំងទប់ទល់ តែនៅតែបរាជ័យថយទ័ពចុះទន្លេអ៊ុយប្រាត (EuPhrate) ទៅ (ព. ស. ២១០ មុន គ. ស. ៣៣៣) ។

# សេចក្តីកាត់ហេតុប្លែកៗ

(តមក)

ព្រះបាទកនិស្កៈ — នេះជាព្រះនាមរបស់មហាក្សត្រដែលមានកេរ្តិ៍ព្រះនាមល្បីល្បាញ ១ អង្គក្នុងប្រទេសឥណ្ឌាខាងជើង រហូតដល់ស្រុកទីបេត៍ ស្រុកចិនទីងស្រុកម៉ុង្គូលី ព្រោះមហាក្សត្រអង្គនេះ ទ្រង់ជាអ្នកផ្តើមធ្វើពុទ្ធសង្គាយនា (ប៉ែកខាងមហាយាន។) ដែលបានប្រជុំនៅស្រុកកស្មីរៈ ៗ មហាក្សត្រអង្គនេះគ្រងរាជសម្បត្តិក្នុង ព.ស.៦២១ គង់នៅក្នុងក្រុងបុរុសបុរៈ (ឥឡូវនេះហៅថា ប៉េសាវ៉រ) ក្នុងដែនគន្ធារៈ ទ្រង់ជាក្សត្រ ១ អង្គទ្រង់មានបុទ្ធានុភាពពង្រីកអាណាចក្រចេញទៅបានឆ្ងាយណាស់ ៗ នៅក្នុងរជ្ជសម័យរបស់ទ្រង់នេះ ពួករាជបរិវាររបស់ទ្រង់ប្រតិបត្តិតាមសាសនាព្រាហ្មណ៍ក៏មាន តាមពុទ្ធសាសនាក៏មាន គេទុកដាក់ទ្រង់ជាព្រះបាទអសោកទី ២ ទ្រង់ទំនុកបំរុងព្រះពុទ្ធសាសនាដរាបដល់អស់ព្រះជន្មាយុ ទ្រង់ឲ្យបោះប្រាក់កាសសម្រាប់ចាយមានព្រះពុទ្ធរូបនៅពីលើប្រាក់នោះផង ទ្រង់ឲ្យប្រជុំធ្វើសង្គាយនាដូចយើងបានពោលពីលើរួចមកហើយកាលពី ព.ស.៦៤៣ (ការធ្វើសង្គាយនានេះ) បានធ្វើអដ្ឋកថាអធិប្បាយសេចក្តីពីបាលីនុ៎ះផង ៗ គេយល់ថាទ្រង់បានកសាងវត្ត ប្រាសាទ ចេតិយ យ៉ាងល្អៗ ទុកក្នុងពុទ្ធសាសនាដែរ តែដែលជាកេរ្តិ៍ដំណែលល្បីល្បាញមកដល់យើងសព្វថ្ងៃនេះ គឺការរកឃើញគោដ្ឋ

សម្រាប់ដាក់ព្រះសារីរិកធាតុរបស់ព្រះពុទ្ធជាម្ចាស់ ហើយនៅលើកោដ្ឋនេះមានឆ្លាក់ព្រះនាមរបស់ទ្រង់ទុកផង ។ ប្រយោជន៍ដែលទ្រង់បានធ្វើទុកដល់ព្រះពុទ្ធសាសនានេះនាំឲ្យពន្លឺរស្មីនៃព្រះពុទ្ធសាសនាផ្សាយទៅពេញប្រទេសឥណ្ឌា និងប្រទេសចិនផង ។

**តណ្ឌីក្នុងកោះលង្កា**— តណ្ឌីជាឈ្មោះក្រុងយ៉ាងល្អមួយនៅលើមាត់បឹងមួយ ក្នុងតំបន់ដែលដេរដាសដោយភ្នំ នៅខាងលើស្រុកកូឡុម្បូ ។ នៅតំបន់ដែលមានភ្នំច្រើននេះហើយពីដើមមកលំបាកនឹងចូលទៅដល់ទីនោះ តែទីនោះជាទីប្រថាប់នៃស្តេចលង្កាជាច្រើន តាំងអំពី ព.ស. ១១៣៥ ដល់២៣៤៨ ។ ក្នុងសម័យដែលកំពុងរំកើបញាប់ញ័រដោយខ្មាំងសត្រូវ ហើយក្នុងខណៈនោះគេបានហៅជនជាតិប្រទេសក្រៅ ឲ្យមកជួយច្បាំងនឹងពួកខ្មាំងសត្រូវជាតិទមិឡ (ក្រុងនៅទិសខាងត្បូង) គឺហៅពួកពរទុ-គេស, ហុល្លង់ដេស, អង់គ្លេស ។ ពួកបច្ចាមិត្រដែលត្រូវការឡើងសោយរាជ្យអស់នោះសុទ្ធតែមានឈាមឥណ្ឌាខាងត្បូង ហើយទុកជាអ្នកគិតដល់ពុទ្ធសាសនិកជនទាំងឡាយដែរ តែជនពួកនេះមានសេចក្តីគោរពដល់សាសនាព្រាហ្មណ៍ខ្លាំងណាស់ ។

ពាក្យថា "គណ្ឌី" ជាពាក្យក្លាយមកពីឈ្មោះវាស់របស់ក្រុង ។ មានវិហារពីរ វិហារ ១ ហៅថា អស្គិរិយៈ ហើយវិហារមួយទៀតហៅថា ម័លវត្តិវិហារ តែរបស់ដែលនាំឲ្យគណ្ឌីមានកេរ្តិ៍ឈ្មោះល្បីល្បាញនោះ គឺប្រាសាទមួយដែលជាទីដំកល់ព្រះចង្កូមកែវរបស់ព្រះពុទ្ធជាម្ចាស់ ដែលគេធ្លាប់ហៅថា ទលទាមលិគាវៈ ។ យើងមិនបាច់ដំណាលពីព្រះចង្កូមកែវនេះទៀតទេ ដ្បិតព្រះពជបណ្ណាល័យបានបោះពុម្ពប្រវត្តិព្រះចង្កូមនេះជាពាក្យកាព្យសព្វគ្រប់ហើយ ដែលលោកគ្រូមហាពិនបានរៀបរៀង ជំ-ថ្លៃក្នុង ១ ក្បាលត្រឹម ១០ សេនប៉ុណ្ណោះ ។

## មក្កលីផល

មក្កលីផលនេះជាសាស្ត្រាល្បែងមួយរបស់ខ្មែរ ជារឿងជាន់ចាស់មួយមាននៅក្នុងស្រុកខ្មែរ ឥឡូវគេបានប្រែរឿងនេះជាភាសាបារាំងសែស ប្រជាជននៅក្រុងប៉ារីសមានសេចក្ដីសរសើររឿងនេះណាស់ ដោយមានសំបុត្រមួយដែលគេបានផ្ញើមកដល់សំឡាញ់ម្នាក់នៅស្រុកខ្មែរនេះ ។

ប្រសិនបើយើងស្រង់យកដំណឹងនេះមកផ្សាយនឹងនាំឲ្យខ្មែរសប្បាយចិត្តពល់គ្នាមិនខាន ដូចគេនិយាយថា "កាលណាខ្ញុំក្រោកឡើងទៅមើលឃើញក្រុងប៉ារីស, ហាក់ដូចជាប្រាសាទនគរនៅជិតយើងបង្កើយ, ហើយកាលណាខ្ញុំងាកមើលទៅទន្លេសែន (ទន្លេដែលហូរកាត់ក្រុងប៉ារីស, ដូច

ទន្លេមេគុងនៅ(ក្រុងភ្នំពេញនេះដែរ) តែនេះគឺទន្លេមេគុងទេ ដែលធ្វើទឹកចិត្តខ្ញុំឲ្យជោរជន់ឡើង" ។

នេះជាដំណើរល្អមួយដែលធ្វើឲ្យគេមានចិត្តទឹករលឹកដល់ស្រុកខ្មែរជានិច្ច ។

## អំពីសៀវភៅពង្សាវតារសព្វថ្ងៃនេះ

កាលជាន់ដើម ពួកក្មេងដែលរៀនពង្សាវតារអំពីប្រទេសរបស់ខ្លួន តាមលំដាប់លំដោយរឿងចម្បាំងដែលកើតឡើងនឹងប្រទេសជិតខាង ទំនងនេះជាគ្រឿងធ្វើគំនិតក្មេងឲ្យមានចិត្តព្យាបាទ ។ ប៉ុន្តែមកដល់សព្វថ្ងៃនេះ គេអាចនិយាយបានថា គេមិនធ្វើដូច្នោះទេ គឺពួកគ្រូបង្រៀនតែងណែនាំចិត្តគំនិតក្មេងទៅរកសេចក្តីចំរើនប្រកបដោយសន្តិភាពវិញ ។ គំនិតនេះទុកស្មើដោយឱវាទរបស់ព្រះពុទ្ធជាម្ចាស់ ។ ក្នុងពង្សាវតារបារាំងសែសមួយ ដែលគ្រូបង្រៀនបារាំងសែសពីរនាក់ បានបោះពុម្ពផ្សាយដូចមានសេចក្តីដូច្នេះថា "ប្រជាជននានាជាតិកាន់តែជិតជាប់គ្នាតាំងពីសតវត្សរ៍ទី ១៩ (ព. ស. ២៣៤៣) ដោយមានផ្លូវគមនាគមចំរើនឡើងហើយកាន់តែស្រួលបួលឡើងផងតាំងក្នុងខណៈនោះនិងខាងក្រោយចម្បាំងតមកប្រជាជនតែងឆ្លងទៅកាន់គ្នាទៅវិញទៅមក មានគួរយ៉ាងដែលយើងយល់ច្បាស់ថា យើងត្រូវការប្រែងកាត់អំពីប្រទេសអាមេរិកនិងប្រទេសមេក្សិក នឹង

ធ្យូងថ្មអង់គ្លេស ចុះហេតុអ្វីនៅតែធ្វើឲ្យប្រជាជនគោងតែទទួលធ្វើសង្គ្រាម អំពីរឿងអស់នេះ?- ពួកយើងប្តូរនាំគ្នាម្ចាប់សឹកសង្គ្រាម ដែលប្រកបដោយមហាភ័យយ៉ាងសំបើមនេះវិញ ហើយយើងនាំគ្នារក្សាទុកនូវសន្តិ-ភាពដែលតែងធ្វើយើងឲ្យមានសេចក្តីសប្បាយរីករាយពល់គ្នា ក្នុងការងាររបស់ខ្លួន ។

## ដីមានបិសាប

មានមហាអ្នកប្រាជ្ញបារាំងសែសម្នាក់ ឈ្មោះអ្នកស្រីក្រុំកាឡាទី ដែលទើបមកធ្វើការនៅស្រុកខ្មែរ ក្នុងឆ្នាំ ១៩៣៩ នេះឯង បានធ្វើសេចក្តីកត់ហេតុមួយទុកថា នៅក្នុងខែត្រតាកែវ ជិតភូមិស្វាយយ៉ុំងកល្យដែលនៅលើដីទួលមួយមានទំហំធំជាងមួយគីឡូម៉ែត្រក្រឡា មានដំណាំព្រៃដុះទ្រុបទ្រុល នៅទីនោះមានស្រះឈូកមួយនឹងស្ទឹងមួយព័ទ្ធជុំវិញដីទួល ចៅហ្វាយខែត្របានដំណាលសេចក្តីប្រាប់ថា ដីនេះមានបិសាចកាចណាស់ មានអ្នកស្រុកមកសង់ផ្ទះមួយនៅទីនេះ ផ្ទះនោះក៏បាក់ខ្ទេចខ្ទីទៅ មនុស្សពីរនាក់ត្រូវទទួលគ្រោះថ្នាក់ជាទម្ងន់ ។ មានរឿងមួយទៀតថា មានកើតភ្លើងឆេះហិនហោចអស់ទៅ ហើយនៅទីបំផុត អ្នកស្រុកគិតកសាងជាវត្តមួយល្អមើល ក៏នៅតែកសាងមិនកើតទៀត ។ សេចក្តីដែលពោលមកនេះមានទំនងដូចជាគេហៅថាយក្សក្នុងរឿងព្រេងនុ៎ះឯង ។

# សុភាសិត

“ការមើលសៀវភៅល្អៗទុកដូចជាការសាកច្ឆាទាំងពួកមនុស្សដ៏សុចរិតស្មោះត្រង់បំផុតកប់ជាច្រើនសតវត្សរ៍មកហើយ”

សុភាសិតនេះជារបស់លោក ដេស្កាត ជាប្រាជ្ញាមេធី ជាតិបារាំងសែសដ៏ល្បីល្បាញ អនិច្ចកម្មកាលពី ព.ស. ២១៩៣ ។

លោកនេះចូលចិត្តធ្វើដំណើរទាំងចូលទៅមើលប្រទេសធំៗនៅអឺរុបកណ្តាល ។ លោកបានធ្វើការសំខាន់ៗតាមមុខក្រសួងរបស់ប្រាជ្ញាមេធី ដែលត្រូវរុករកសេចក្តីពិត ឯហេតុផលជាគ្រឿងប្រដាប់សម្រាប់វិជ្ជាសាកល ។ លោកនេះជាអ្នកប្រាជ្ញធំមួយដែលចេះវិជ្ជាប្រែប្រួលរូបនៃពន្លឺនឹងឥន្ទធនូ ។

“ព្រះអាទិត្យមិនដែលរង់ចាំពាក្យអង្វរសុំរបស់ជនទាំងតួនដែលស្រែកសុំឲ្យបញ្ចេញពន្លឺរស្មីឬកំដៅថ្ងៃដល់ម្តងឡើយ (គឺលោកតែងតែបញ្ចេញពន្លឺរស្មីតាមពេលម៉ោងរបស់លោកជានិច្ច) ។ ចូរអ្នកខំធ្វើសេចក្តីចំរើនទាំងតួនដូច្នោះដែរ កុំបាច់ឲ្យគេមកដាស់តឿនក្រើនរំលឹកដល់អ្នកឡើយ” ។

សុភាសិតនេះ របស់លោកអេពីគែត អនិច្ចកម្មទៅកាលពី ព.ស. ៦៥០ លោកនេះនៅក្នុងក្រុងរោម ដែនប្រទេសឥតាលីពីបុរាណ ។ លោកជាអ្នកប្រាជ្ញប្រាជ្ញាមេធីមួយយ៉ាងធំក្នុងសម័យបុរាណ មានកេរ្តិ៍ឈ្មោះល្បី

ល្បាញក្នុងការមិនអាល័យព្រួយនឹងទុក្ខលំបាកឈឺចាប់ ហើយលោកជាអ្នកតឹងតែងណាស់ លោកត្រូវការឲ្យមនុស្សចៀសវាងពីសេចក្ដីលោភ ហើយលោកចង់ឲ្យមនុស្សបណ្ដុះធម៌មេត្តា នឹងយល់ថា អ្នកប្រាជ្ញប្រាជ្ញា-មេធីត្រូវតែបង្រៀនសេចក្ដីពិតនឹងធ្វើគំរូល្អទុក ។

*
*　*

«វិធីធ្វើការសងសឹកដ៏ប្រសើរនោះ គឺការមិនយកគម្រាប់តាមពួកមនុស្សពាល » ។

«កាលវេលាមិនមែននៅឆ្ងាយពីទីណា ដែលអ្នកក្លួចជនទាំងពួង ហើយពេលវេលានេះសោតទៀត ក៏មិនមែននៅឆ្ងាយពីទីណាដែលជនទាំងពួងក្លួចអ្នកដែរ» ។

សុភាសិតល្អៗនេះ ដែលស្ដេចចក្រពត្តិកេមុាំងទ្រង់ពិចារណាតែងឡើង ស្ដេចចក្រព្រះអង្គនេះព្រះនាមម៉ាកអូរ៉េល ទ្រង់សោយរាជ្យពីពុទ្ធ-សករាជ ៧០៤ ដល់ ព.ស. ៧២៣ ។ ទ្រង់ជាមហាក្សត្រដែលមានជ័យជំនះយ៉ាងធំ ១ អង្គ ទ្រង់ប៉ិនប្រសប់ត្រួតការឃ្លាំងនឹងយុត្តិធម៌ ។ ទ្រង់ការពារបែបបទនាផ្សេងៗ នឹងអក្សរសាស្ត្រ ទ្រង់បានសរសេរសេចក្ដីកត់ហេតុមួយដោយព្រះអង្គឯងទាំងអស់ តែទ្រង់មិនទាន់បានបោះពុម្ពផ្សាយ។

សេចក្ដីកត់ហេតុនេះនេបាទធ្វើជាកូនសៀវភៅតូចមួយយ៉ាងល្អពេញទៅ ដោយសេចក្ដីត្រៀវត្រាតសុចរិតស្មោះត្រង់នឹងមេត្តាចិត្ត ។

សុភាសិតដែលយើងបានពោលទុកខាងលើនេះ អាចប្រហែល ៗ នឹងសុភាសិតខាងព្រះពុទ្ធសាសនាដែរ ។

# រឿងបុរសពីរនាក់តាមខ្ញុំរត់

មាននិទាន១ថា មានបុរសពីរនាក់ ម្នាក់តាមខ្ញុំរត់ ម្នាក់តាមគោរត់ ទៅប្រទះគ្នានៅលើស្ពាន ម្នាក់ថាត្រូវឯងចៀសអញៗ តាមខ្ញុំរត់បាត់ ម្នាក់ថាចៀសអញៗ តាមគោរត់បាត់ ៗ បុរសទាំងពីរពុំចៀសគ្នាឡើយ នាំគ្នាទៅប្តឹងចៅក្រមៗ មិនអាចជំនុំជំរះសេចក្តីនោះបាន ទើបបណ្តេញចៅទាំងពីរថា ឯងជាម្ចាស់ខ្ញុំរត់ត្រូវទៅតាមខ្ញុំទៅ ឯម្ចាស់គោរត់ត្រូវទៅតាមគោទៅ ៗ ចៅទាំងពីរពុំសុខចិត្តឡើយ ទើបចៅក្រមនាំឡើងទៅក្រាបទូលសម្តេចព្រះមហាក្សត្រាធិរាជ ចៅទាំងពីរក្រាបទូលដោយទំរង់ដំណើរនោះហើយ ទើបព្រះអង្គមានព្រះបន្ទូលសួរថា ហេតុអ្វីក៏ព្រះស្តែងទាំងពីរកើតក្តីនឹងគ្នា ចៅម្នាក់ក្រាបទូលថាសូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំជាខ្ញុំនេះតាមខ្ញុំរត់ ចៅម្នាក់ទៀតក្រាបទូលថាទូលព្រះបង្គំជាខ្ញុំនេះតាមគោរត់ ៗ ព្រះអង្គត្រាស់សួរទៀតថា កាលគោព្រះស្តែងរត់តើវាសួរស្ពានឬវាហែលទឹក បុរសនោះថាគោទូលព្រះបង្គំជាខ្ញុំហែលទឹក ចុះខ្ញុំព្រះស្តែងវាដើរលើស្ពានឬហែលទឹក បុរសម្នាក់ទៀតថាខ្ញុំទូលព្រះបង្គំជាខ្ញុំវាសួរស្ពានដើរទៅ ទើបព្រះអង្គបង្គាប់ឲ្យចៅតាមគោនោះសងខ្ញុំគេ ដ្បិតខ្ញុំរត់នោះវាសួរស្ពានដើរទៅ ឯគោរត់នោះវាសួរស្ពានពុំបានឡើយ ៗ ចៅទាំងពីរចូលចិត្តហើយក្រាបថ្វាយបង្គំនាំគ្នាទៅកាន់លំនៅទីទៃៗ ៗ រីសម្តេចព្រះមហាក្សត្រាធិរាជព្រះអង្គបង្គាប់សេចក្តីដូច្នេះ នេះហៅសុគតិគមន៍ហោង ៗ